ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ២៤ ត្រីមាសទី០១ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

## ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ៦-៤-២០២៦ | -ព្រះរាជក្រម នស/រកម/០៤២៦/០០៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា | ២៨៤៥ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១២-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៥៤ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ឹង សម្បត្តិ** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ដោយពុំទទួលប្រាក់បំណាច់មុខងារ | ២៨៥៤ |
| ១២-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៥៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់បុគ្គលិកអង្គការដៃគូអភិវឌ្ឍ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ៤រូប | ២៨៥៥ |
| ១២-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៥៧ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **រស់ តីរុណា** ជាអនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៨៥៦ |
| ១២-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៥៨ ស្តីពី ការតែងតាំងមុខតំណែង និងផ្តល់ឋានៈដល់ឯកឧត្តម **យ៉េត ទីណែល** ជាអគ្គលេខាធិការនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (គ.ល.ក.) មានឋានៈស្មើ រដ្ឋលេខាធិការ | ២៨៥៧ |
| ១៣-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៥៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ៤រូប | ២៨៥៨ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៦០ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ឡាយ គឹមលី** ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ២៨៥៩ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៦៦ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍ដល់លោក **ហ៊ុន សាម៉ុល** នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា | ២៨៦០ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៦៧ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់មន្ត្រីរាជការ ២រូប នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់សាមីខ្លួន | ២៨៦១ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៦៨ ស្តីពី ការតែងតាំងនិងផ្តល់ឋានៈឯកឧត្តម **សៅ ថារី** ជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ អគ្គនាយក | ២៨៦២ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៦៩ ស្តីពី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដល់មន្ត្រីរាជការ ១៨រូប និងនិយ័តកម្មដំឡើងថ្នាក់ តាមអតីតភាពការងារ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដល់មន្ត្រីរាជការ ៣រូប | ២៨៦៣ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧០ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ឈុំ ឆុនលី** ពីអនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឈុំ ឆុនលី** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ | ២៨៦៥ |

| | | |
|---|---|---|
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ប្រគេន ព្រះគ្រូសមថភិរក្ខធម្ម **ទ៉ាត បញ្ញាវ័ន្ត** | ២៨៦៧ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃរដ្ឋបាលខេត្តព្រះវិហារ ៤៧រូប | ២៨៦៨ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ជាកិច្ចបច្ឆាមរណៈ ចំពោះ វរសេនីយ៍ទោ **ឃី សុថាត់** | ២៨៧០ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃគណៈកម្មាធិការជាតិអេស្កាប់ ៦រូប | ២៨៧១ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនមន្ត្រីរាជការ សប្បុរសជន ១៩៨អង្គ/រូប | ២៨៧២ |
| ១៧-៣-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣២៦/៣៧៧ ស្តីពី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដល់មន្ត្រីរាជការ ១៦៩រូប | ២៨៧៦ |

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

| | | |
|---|---|---|
| ៦-៣-២០២៦ | -អនុក្រឹត្យលេខ ៣៥ អនក្រ.បក ស្តីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលស្ថិតក្នុងភូមិសាស្ត្រខេត្តត្បូងឃ្មុំ | ២៨៨៣ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា | ២៨៨៨ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២០៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៨៩១ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២០៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៨៩៨ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២០៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ២៩០០ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២០៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩០២ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា | ២៩០៨ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩០៩ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩១៣ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩១៦ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩២០ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩២៣ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩២៥ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ២៩២៨ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៩២៩ |
| ៣-៣-២០២៦ | -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ២៩៣១ |

### ២~សេចក្តីសម្រេច

| | | |
|---|---|---|
| ២៣-២-២០២៦ | -សេចក្តីសម្រេចលេខ ២៣ សសរ ស្តីពី ការចាត់តាំងបន្ថែមសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ | ២៩៤៥ |

### ៣~ផែនការ

១៣-២-២០២៦ -ផែនការលេខ ០១ ផក ស្តីពី យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ ២៩៤៧

## III~ការងារបណ្ដាក្រសួង

### ១~ ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-១២-២០២៥ -ប្រកាសអន្តរក្រសួងលេខ ១០៣៦ សហវ.ប្រក.អរតន ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស សម្រាប់បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យ សង្គមកិច្ចនិងវប្បធម៌ជូនមន្ត្រីរាជការប្រចាំនៅអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃ ក្រសួងមុខងារសាធារណៈ ២៩៥៦

១៧-១២-២០២៥ -ប្រកាសអន្តរក្រសួងលេខ ១០៣៧ សហវ.ប្រក.អរតន ស្តីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន នៅអគ្គាធិការដ្ឋាន ជាអាណាប័កផ្ទេរសិទ្ធិពេញលេញ នៃក្រសួងមុខងារសាធារណៈ ២៩៥៩

### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២៨-១១-២០២៥ -ប្រកាសលេខ ៨១៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវើហ្គ្រេន បាយស៊ីខល (ខេមបូឌា) ឯ.ក បង្កើតរោងចក្រដំឡើងទោចក្រយាន ទោចក្រយានអគ្គិសនី និងផលិតគ្រឿង បង្គុំទោចក្រយាន ២៩៦២

# ព្រះរាជក្រម

នស/រកម/០៤២៦/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១.- គោលបំណង

ច្បាប់នេះកំណត់អំពីវិធានផ្នែកព្រហ្មទណ្ឌដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា សំដៅចូលរួមថែរក្សាការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។

### មាត្រា២.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបទល្មើសឆបោកដែលត្រូវបានប្រព្រឹត្តតាមប្រព័ន្ធបច្ចេកវិទ្យា ឬដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយដើម្បីប្រព្រឹត្តបទល្មើស ព្រមទាំងចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

បទល្មើសដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់នេះ គឺជាបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងករណីណាមួយដូចខាងក្រោម៖

១-បទល្មើសត្រូវបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន។

២-បទល្មើសត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីណាមួយដូចខាងក្រោម៖
- បទល្មើសត្រូវបានប្រព្រឹត្តដោយពលរដ្ឋខ្មែរ។
- បទល្មើសត្រូវបានប្រព្រឹត្តលើពលរដ្ឋខ្មែរ។
- ទ្រព្យសម្បត្តិដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស ឬផលនៃបទល្មើសដែលមានចែងក្នុងច្បាប់នេះ បានផ្ទេរចូលមកក្នុង ឬបានផ្ទេរចេញពីព្រះរាជាណាចក្រកម្ពុជា។

៣-បទល្មើសត្រូវបានប្រព្រឹត្តដោយប្រើប្រព័ន្ធធនាគារ ឬប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា៣.- យន្តការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

ការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាគឺជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចបង្កើតយន្តការដោយឡែកក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងអនុវត្តការងារបង្ការ ទប់ស្កាត់ និងប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសដែលមានចែងក្នុងច្បាប់នេះ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មនេះ។

ការសម្របសម្រួលសមត្ថកិច្ចរវាងមន្ត្រីនគរបាលយុត្តិធម៌ និងយន្តការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤ .- ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌**

មន្ត្រីរាជការទទួលបន្ទុកការងារបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលបម្រើការងារក្នុងយន្តការដែលត្រូវបានបង្កើតឡើងតាមមាត្រា៣ (យន្តការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) នៃច្បាប់នេះ ទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីពិនិត្យ ស៊ើបអង្កេត និងស្រាវជ្រាវបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីរាជការបម្រើការងារក្នុងយន្តការនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការធ្វើសម្បថ និងការអនុវត្តការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៣
## បទល្មើសទាក់ទងនឹងអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា

**មាត្រា៥ .- បទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**

អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឧបាយកលទុច្ចរិត ដែលត្រូវបានប្រព្រឹត្តតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ឬដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាជាមធ្យោបាយ ក្នុងគោលបំណងទទួលបាននូវ៖

១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

២-ការផ្គត់ផ្គង់សេវា។

៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល។

អំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយប៊ីលាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្ត៖

១-ដោយមានការរៀបចំជាក្រុមមានការចាត់តាំង។

២-ដោយមានជនរងគ្រោះច្រើននាក់។

**មាត្រា៦ .- បទរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**

អំពើរៀបចំ ឬដឹកនាំទីកន្លែងឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលមានលក្ខណៈប្រមូលផ្តុំ ឬក្នុងទម្រង់ជាមជ្ឈមណ្ឌល ដែលអនុញ្ញាតឱ្យបុគ្គលច្រើននាក់ចងក្រងគ្នាជាក្រុម ឬជាបណ្តាញ ទោះមាន ឬគ្មានរចនាសម្ព័ន្ធក្រុមជាក់លាក់ក៏ដោយ ដើម្បីប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវកំណត់ជាបទល្មើសរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយប៊ីលាន) រៀល។

ត្រូវចាត់ទុកថាជាបទល្មើសរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសដែលមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះផងដែរ ចំពោះអំពើរៀបចំ ឬដឹកនាំទីកន្លែងដាច់ដោយឡែកៗពីគ្នាដើម្បីប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ប៉ុន្តែអាចចងក្រងគ្នាជាបណ្តាញតាមគ្រប់រូបភាព ទោះបីពុំមានលក្ខណៈប្រមូលផ្តុំគ្នាក្នុងទម្រង់ជាមជ្ឈមណ្ឌលក៏ដោយ។

អំពើរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ ០០០ (មួយប៊ីលាន) រៀល ទៅ ២ ០០០ ០០០ ០០០ (ពីរប៊ីលាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ

១-ដោយប្រើអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

២-ដោយមានការចាប់ ការឃុំឃាំង ឬការបង្ខាំង។

៣-ដោយមានការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស ការកេងចំណេញលើពលកម្ម ការធ្វើអំពើបង្ខិតបង្ខំឱ្យធ្វើសកម្មភាពខុសពីឆន្ទៈ ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត។

អំពើរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយបណ្តាលឱ្យមានមនុស្សស្លាប់ម្នាក់ ឬច្រើននាក់។

**មាត្រា៧ .. បទជ្រើសរើស ឬបណ្តុះបណ្តាលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**

អំពើជ្រើសរើស ឬបណ្តុះបណ្តាលអ្នកដទៃក្នុងគោលបំណងឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល។

អំពើជ្រើសរើស ឬបណ្តុះបណ្តាលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយប៊ីលាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ

១-ដោយប្រើអំពើហិង្សា ទារុណកម្ម ឬអំពើឃោរឃៅ។

២-ដោយមានការចាប់ ការឃុំឃាំង ឬការបង្ខាំង។

៣-ដោយបណ្តាលឱ្យមានមនុស្សស្លាប់។

៤-ដោយដឹងថាបុគ្គលដែលត្រូវបានជ្រើសរើស ឬបណ្តុះបណ្តាល គឺជាជនរងគ្រោះនៃអំពើរត់ពន្ធមនុស្ស ឬអំពើជួញដូរមនុស្ស។

**មាត្រា៨ .. បទប្រមូលក្នុងចេតនាទុច្ចរិតនូវឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ ៣០០ ០០០ ០០០ (បីរយលាន) រៀល ចំពោះបុគ្គលដែលប្រមូលនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ ក្នុងគោលបំណងប្រើប្រាស់ ឬបង្កើត[illegible]អាទ៏នូវគណនីធនាគារ គណនីអនឡាញ វេបសាយ គណនីអេឡិចត្រូនិក ឬគណនីម[illegible]នានា សម្រាប់ជាមធ្យោបាយប្រព្រឹត្តបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

អំពើប្រមូលក្នុងចេតនាទុច្ចរិតនូវឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៣០០ ០០០ ០០០ (បីរយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយក្រុមមានការចាត់តាំង។

**មាត្រា៩ .. បទសម្អាតប្រាក់ពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងច្បាប់នេះ**

ត្រូវចាត់ទុកថាជាទម្រង់មួយនៃបទល្មើសសម្អាតប្រាក់ និងត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសសម្អាតប្រាក់ ក្នុងករណីដែលម្ចាស់ទ្រព្យមិនមានភស្តុតាងបង្ហាញអំពីប្រភពស្របច្បាប់នៃទ្រព្យ ដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស ឬជាផលនៃបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬបទល្មើសពាក់ព័ន្ធផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា១០ .. ទោសបន្ថែម**

ចំពោះជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងចាប់ពីមាត្រា៥ (បទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) ដល់មាត្រា៨ (បទប្រមូលក្នុងចេតនាទុច្ចរិតនូវឯកសារសម្គាល់អត្តសញ្ញាណ ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ) នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។

តុលាការអាចប្រកាសរឹបអូសជាទ្រព្យសម្បត្តិរដ្ឋនូវអចលនវត្ថុដែលត្រូវបានប្រើប្រាស់ជាទីតាំង ឬមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

តុលាការអាចសម្រេចបិទ ឬលុបគណនីធនាគារ គណនីអនឡាញ វេបសាយ គណនីអេឡិចត្រូនិក ឬគណនីបណ្តាញសង្គមនានា ដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយប្រព្រឹត្តបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងដែលត្រូវបានបង្កើតឡើងដោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬឯកសារព័ត៌មានផ្ទាល់ខ្លួននានារបស់អ្នកដទៃ។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា១១ .. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៥ (បទឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) ដល់មាត្រា៩ (បទសម្អាតប្រាក់ពាក់ព័ន្ធនឹងបទល្មើសដែលមានចែងក្នុងច្បាប់នេះ) នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ ០០០ (មួយប៊ីលាន) រៀល ទៅ ៣០ ០០០ ០០០ ០០០ (សាមសិបប៊ីលាន) រៀល ឬរហូតដល់ស្មើនឹងតម្លៃមូលនិធិ ឬទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា១២ .. ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដូចមានចែងក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមបាន

**មាត្រា១៣ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិត**

សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិតនៃបទល្មើសដូចមានចែងក្នុងច្បាប់នេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។

**មាត្រា១៤ .- ការប្រកាសមូលទោស**

បទប្បញ្ញត្តិនៃមាត្រា៩៧ (ការប្រកាសមូលទោស) នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ។ ការប្រកាសមូលទោសត្រូវអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

មូលទោសចំពោះបទល្មើសទាំងឡាយដូចមានចែងក្នុងច្បាប់នេះ មិនអាចត្រូវបានជំនួសដោយទោសជំនួស ឬទោសបន្ថែមតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឡើយ។

**មាត្រា១៥ .- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនដែលត្រូវបានបង្ខំឱ្យធ្វើសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា**

ជនដែលបានចូលរួមប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ មិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះឡើយ ដោយអនុវត្តស្របតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមាន។

**មាត្រា១៦ .- ការលើកលែងឱ្យរួចផុតពីទោស និងស្ថានសម្រាលទោស**

បុគ្គលណាដែលបានចូលរួមប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងមាត្រា៦ (បទរៀបចំ ឬដឹកនាំមជ្ឈមណ្ឌលឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) និងមាត្រា៧ (បទជ្រើសរើស ឬបណ្ដុះបណ្ដាលអ្នកដទៃឱ្យចូលរួមប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា) នៃច្បាប់នេះ ត្រូវលើកលែងឱ្យរួចផុតពីការទទួលទោស ប្រសិនបើមុនការចោទប្រកាន់ បុគ្គលនោះបានបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ចអំពីអត្ថិភាពនៃអំពើនេះ ហើយបាននាំឱ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត ឬអាចនាំឱ្យប្រមូលមកវិញបាននូវផលនៃបទល្មើស។

ប៉ុន្តែ បុគ្គលនោះត្រូវទទួលបាននូវស្ថានសម្រាលទោស ប្រសិនបើការបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ចខាងលើធ្វើឡើងក្រោយការចោទប្រកាន់។ អានុភាពនៃស្ថានសម្រាលទោសនេះ ត្រូវអនុវត្តស្របតាមក្រមព្រហ្មទណ្ឌ។

**ជំពូកទី៤**
**បទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ**

**មាត្រា១៧ .- នីតិវិធីនៃការអនុវត្ត**

នីតិវិធីសម្រាប់អនុវត្តចំពោះការពិនិត្យ ការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្ដន្ទាទោសចំពោះបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបទល្មើសពាក់ព័ន្ធផ្សេងទៀតដូចមានចែងក្នុងច្បាប់នេះ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់នេះ។

**មាត្រា១៨ .. ការឃាត់ខ្លួន**

ការឃាត់ខ្លួនត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ផ្អែកតាមតម្រូវការចាំបាច់នៃការអនុវត្តនីតិវិធី រយៈពេលនៃការឃាត់ខ្លួនអាចពន្យារពេលរៀងរាល់ ៤៨ (សែសិបប្រាំបី) ម៉ោងម្តង ដោយមានការអនុញ្ញាតពីព្រះរាជអាជ្ញា ក្នុងករណីដូចតទៅៈ

- បទល្មើសត្រូវបានប្រព្រឹត្តដោយក្រុមមានការចាត់តាំង ឬដោយមានជនសង្ស័យច្រើននាក់។
- បទល្មើសត្រូវបានប្រព្រឹត្តដោយមានជនរងគ្រោះច្រើននាក់។

រយៈពេលសរុបនៃការឃាត់ខ្លួនមិនត្រូវលើសពី ១០ (ដប់) ថ្ងៃ។

ការពន្យារពេលនៃការឃាត់ខ្លួនគឺជាវិធានការពិសេស។ រាល់ការពន្យារពេលនៃការឃាត់ខ្លួនត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាពឱ្យបានច្បាស់លាស់ និងយោងលើតម្រូវការចាំបាច់ក្នុងការអនុវត្តនីតិវិធី។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវកត់ត្រាចូលក្នុងកំណត់ហេតុឃាត់ខ្លួនអំពីការសម្រេចរបស់ព្រះរាជអាជ្ញាដែលអនុញ្ញាតឱ្យពន្យារពេលនៃការឃាត់ខ្លួន។

**មាត្រា១៩ .. ការផ្អាក ការឃាត់ទុក និងការបង្កក**

ក្នុងករណីដែលពិនិត្យឃើញមានប្រតិបត្តិការសង្ស័យ ឬដើម្បីទប់ស្កាត់ការផ្ទេរចេញនូវសាច់ប្រាក់ពីគណនីដែលសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើស ឬផលនៃបទល្មើសដែលមានកំណត់ក្នុងច្បាប់នេះ មន្ត្រីនគរបាលយុត្តិធម៌ អាចស្នើសុំដោយផ្ទាល់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឱ្យផ្អាកជាបណ្តោះអាសន្ននូវប្រតិបត្តិការសង្ស័យ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវធ្វើការផ្អាកប្រតិបត្តិការនោះភ្លាមៗដោយគ្មានបង្អង់។ ការផ្អាកប្រតិបត្តិការសង្ស័យ មានរយៈពេលមិនលើសពី ៤៨ (សែសិបប្រាំបី) ម៉ោង។ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីសម្រេចអំពីការឃាត់ទុកគណនី ឬស្នើសុំទៅតុលាការដើម្បីសម្រេចបង្កកគណនីនោះ។ តុលាការអាចសម្រេចអំពីការឃាត់ទុក និងការបង្កកគណនីនេះដោយឯកឯងបាន។

ក្នុងករណីដែលពិនិត្យឃើញមានទ្រព្យសម្បត្តិ ឬប្រតិបត្តិការសង្ស័យផ្សេងទៀតជាប់ពាក់ព័ន្ធបទល្មើស ឬផលនៃបទល្មើសដែលមានកំណត់ក្នុងច្បាប់នេះ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីឃាត់ទុកទ្រព្យសម្បត្តិ ឬផ្អាកប្រតិបត្តិការទាំងនោះជាបណ្តោះអាសន្ន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការជាបន្ទាន់ដើម្បីឃាត់ទុកទ្រព្យសម្បត្តិ ឬផ្អាកប្រតិបត្តិការទាំងនោះជាបណ្តោះអាសន្ន។

តុលាការត្រូវសម្រេចអំពីការឃាត់ទុក ឬការបង្កកគណនីឬទ្រព្យសម្បត្តិនេះ ក្នុងរយៈពេលមិនលើសពី ៤៨ (សែសិបប្រាំបី) ម៉ោង គិតពីថ្ងៃទទួលពាក្យស្នើសុំ ឬពាក្យបណ្តឹង។ រយៈពេលនេះអាចពន្យារពេលបានមិនលើសពី ២៤ (ម្ភៃបួន) ម៉ោង ចំពោះបទល្មើសដែលមានលក្ខណៈស្មុគស្មាញ។

ម្ចាស់គណនី ម្ចាស់ទ្រព្យសម្បត្តិ ឬតតិយជនដែលមានប្រយោជន៍ពាក់ព័ន្ធ អាចប្តឹងតវ៉ាចំពោះការសម្រេចរបស់តុលាការដូចមានកំណត់ក្នុងកថាខណ្ឌខាងលើនេះ បន្ទាប់ពីបានទទួលដំណឹងអំពីវិធានការបណ្តោះអាសន្ននេះ ដោយអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**មាត្រា២០ .. ការសម្ងាត់វិជ្ជាជីវៈ**

ការសម្ងាត់វិជ្ជាជីវៈ ពុំមែនជាឧបសគ្គរាំងដល់ការអនុវត្តច្បាប់នេះឡើយ។

**មាត្រា២១ .-** កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការជាមួយរដ្ឋបរទេសទាក់ទងនឹងបត្យាប័ន និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ជាអាទិ៍ ការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើស រួមទាំងការប្រមូល និងចែករំលែកព័ត៌មាន ការកំណត់អត្តសញ្ញាណបុគ្គល ការកំណត់អត្តសញ្ញាណទ្រព្យ ការឃាត់ទុកឬបង្កកទ្រព្យ និងការប្រមូលត្រឡប់មកវិញនូវផលនៃបទល្មើសពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ត្រូវអនុវត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ដែលកម្ពុជាជារដ្ឋភាគី។

**មាត្រា២២ .-** ការរឹបអូសទ្រព្យសម្បត្តិ

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្ដឹងសុំតាមដីកាបញ្ជូនទៅតុលាការព្រហ្មទណ្ឌឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិដែលជាមធ្យោបាយប្រព្រឹត្តបទល្មើស ទីតាំងប្រព្រឹត្តបទល្មើស ឬផលនៃបទល្មើសដូចមានចែងក្នុងច្បាប់នេះ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា២៣ .-** ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ក្រៅពីបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ បទប្បញ្ញត្តិនៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវិធានការប្រឆាំងការសម្អាតប្រាក់ដែលពាក់ព័ន្ធនឹងបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៤ .-** ការប្រកាសឱ្យប្រើ និងការអនុវត្តច្បាប់

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវមានអានុភាពអនុវត្តភ្លាម។

ថ្ងៃ *ច័ន្ទ ៤កើត* ខែ *ចេត្រ* ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *០១* ខែ *មេសា* ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្ដីទី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*នស. ២៦០៤. ៤៧៣*

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/ ៣៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **អ៊ីង សម្បត្តិ** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរស. ២៦០៣. ៣៥៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់សុី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/ ៣៥៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់
ដល់បុគ្គលិកអង្គការដៃគូអភិវឌ្ឍ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ៤រូបៈ

ក- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**
លោក **ហ៊ូ គ្រើន**

ខ- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**
១- Mr. Farid Selmi
២- Dr. Iean Russell
៣- Ms. Sanne Sigh

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពសណ. ២៦០៣. ៣៦១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/ ៣៥៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងឯកឧត្តម **រស់ គីរុណា** ជាអនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ :** សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

ចរ.ល. ៧២០៣. ៣៦៧

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/ ៣៥៥

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែង និងផ្ដល់ឋានៈដល់ឯកឧត្ដម **យ៉េត ទីណែល** ជាអគ្គលេខាធិការនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (គ.ល.ក.) មានឋានៈស្មើ រដ្ឋលេខាធិការ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ :** សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**

ពរល. ២៦០៣. ៣៦៣

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/៣៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៤រូបៈ

១- ឯកឧត្តម **ស៊ុន សែនកុសល** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម **ទៀង ជីវី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣- លោកជំទាវ **ស៊ុន ទាសនា** មានឋានៈស្មើ អគ្គនាយក
៤- ឯកឧត្តម **មាន សេរីរិត** មានឋានៈស្មើ អគ្គនាយក។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចរល. ២៦០៣. ៣២៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/ ៣៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងឯកឧត្តម **ឡាយ គឹមលី** ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស. ២៦០៣. ៣៦៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/៣៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៥៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដាក់ឱ្យចូលនិវត្តន៍ដល់លោក **ហ៊ុន សាម៉ុល** អត្តលេខ ១៦៦១៤០០០៣២ នៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៦។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៥ល. ២៦០៣. ៣៧៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/៣៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់ដល់មន្ត្រីរាជការ ០២រូប នៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦៖

១- លោក **តាំង គីមស្រេង** គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៣

២- លោក ថាច់ បណ្ឌុល គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ចរស. ៥២០៣. ៣៧៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រអត/០៣២៦/៣៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **សៅ ម៉ារី** ជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានឋានៈស្មើ អគ្គនាយក។

**មាត្រា២ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ចរល. ២៦០៣. ៣៧៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ឹង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/៣៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** ដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដល់មន្ត្រីរាជការ **០៧ រូប** ចាប់ពីថ្ងៃទី**១៣** ខែមេសា ឆ្នាំ**២០២៦**៖

| | | |
|---|---|---|
| ១-ឯកឧត្តម **លឹម ទិសាល** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២-លោក **ហៀង ដារ៉ា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣-លោក **អ៊ុ សុខា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |

៤-លោក **សេង ម៉ីណ្ណា** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤

៥-លោកស្រី **អ៊ុយ ច័ន្ទបូរ៉ានី** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤

៦-លោក **ខៃ អន** ពីវរមន្ត្រី ថ្នាក់លេខ ១ មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦

៧-លោកស្រី **អ៊ឹម សុក្រជាទី** ពីវរមន្ត្រី ថ្នាក់លេខ ១ មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦។

**មាត្រា២ :** ដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដល់មន្ត្រីរាជការ **១១ រូប** ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦៖

១-ឯកឧត្តម **ណុប ចណ្ណថារ៉ូ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

២-ឯកឧត្តម **ណុប សោភ័ណតារា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៣-លោកស្រី **រិត ត្រីស្ថា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៤-លោក **ម៉ុន រិទ្ធី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៥-លោក **នាង ពុទ្ធារ៉ា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៦-លោក **ម៉ៃ ចណ្ណៈ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៧-ឯកឧត្តម **សូន តារិទ្ធ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤

៨-លោក **ហាម គីមឆេង** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤

៩-លោក **ម៉ុក ពុទ្ធី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤

១០-លោក **អ៊ុល ណារ៉ាក់** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤

១១-ឯកឧត្តម **ជុប សុគន្ធិ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ មកជាថ្នាក់លេខ ៥។

**មាត្រា៣ :** និយ័តកម្មដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ តាមអតីតភាពការងារ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដល់មន្ត្រីរាជការ **០៣ រូប** ចាប់ពីថ្ងៃទី**១៣ ខែមេសា ឆ្នាំ២០២៦**៖

១-លោក **ញ៉ែម គីមតាំ** ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៣

២-លោក **ម៉ន សុមន្ថា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៣-លោក **ដួង ឆារ៉ូ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជាថ្នាក់លេខ ៤។

**មាត្រា៤ :** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស.រកត.០៣.៣៧៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

២/២

បណ្ឌិតសភាចារ្យ **ហ៊ឹង ថូរ៉ាក់ស៊ី**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២៦/៣៧០

យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ឆ្នាំ២០២៥កន្លងទៅ និន្នាការនៃឧក្រិដ្ឋកម្មគ្រឿងញៀនជាសកល នៅតែបន្តប្រែប្រួលស្មុគស្មាញ និងមានកំណើនគួរឱ្យបារម្ភ ជាពិសេសការប្រែប្រួលទាំងរូបភាពនិងសកម្មភាពនៃការផលិត ការកែច្នៃ ការជួញដូរ ប្រកដឹកជញ្ជូនឆ្លងកាត់ និងការពង្រីកភូមិសាស្ត្រនៃការប្រើប្រាស់។

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវជាសកល និងការសន្និដ្ឋានវាយតម្លៃលើលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានឆ្លុះបញ្ចាំងឃើញថា ឥទ្ធិពលគំរាមកំហែងនៃបទឧក្រិដ្ឋគ្រឿងញៀន មិនត្រឹមតែមិនមានសញ្ញាថមថយប៉ុណ្ណោះទេ គឺថែមទាំងបន្តរីករាលដាលកាន់តែធំ កាន់តែគ្រោះថ្នាក់ ពិបាកទប់ទល់ ដែលក្នុងនោះ ពួកឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ បានផ្លាស់ប្តូរវិធីសាស្ត្រថ្មីៗ ក្នុងការពង្រឹងបណ្តាញទំនាក់ទំនង ធ្វើសកម្មភាពប្រទាក់ក្រឡា ដើម្បីផលិត កែច្នៃ ដឹកជញ្ជូន ជួញដូរកាន់តែសកម្ម ជាពិសេសការផ្លាស់ប្តូរវិធីសាស្ត្រក្នុងការផលិត កែច្នៃសារធាតុញៀនប្រភេទថ្មីៗបន្ថែមទៀត ដោយប្រើប្រាស់សារធាតុគីមីផ្សំ សំយោគតាមបែបបច្ចេកវិទ្យាទំនើប ដែលបានបង្កើតនូវស្ថានភាពប្រឈម ប្រកបដោយហានិភ័យកាន់តែខ្លាំង និងកំពុងតែធ្វើឱ្យសហគមន៍អន្តរជាតិចាប់អារម្មណ៍ និងខិតខំខ្នះខ្នែងប្រមូលផ្តុំនូវយុទ្ធសាស្ត្រ ដើម្បីរួមគ្នាដោះស្រាយវិញ្ញាសាដ៏គ្រោះថ្នាក់នេះ សំដៅរក្សាស្ថិរភាពសន្តិសុខ សុវត្ថិភាព សុខុមាលភាពសាធារណៈ និងការអភិវឌ្ឍសង្គមជាសកល។

ព្រះរាជាណាចក្រកម្ពុជា នៅតែជាគោលដៅរងគ្រោះក្រោមឥទ្ធិពលអវិជ្ជមាននៃឧក្រិដ្ឋកម្មដែលមានលក្ខណៈជាសកលនេះនៅឡើយ ដោយត្រូវប្រឈមមុខដោះស្រាយនូវឧបសគ្គដ៏គ្រោះថ្នាក់ដែលមានលក្ខណៈរ៉ាំរ៉ៃយូរអង្វែងនេះ ក៏ដូចជាដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យប្រកបដោយសុច្ឆន្ទៈ ការពារសុខុមាលភាពប្រជាពលរដ្ឋ ការពារលើកស្ទួយមូលធនមនុស្ស ធានាស្ថិរភាពសន្តិសុខ សុវត្ថិភាព និងការអភិវឌ្ឍសង្គមជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការស្តីពី យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ជាបន្តបន្ទាប់ ដែលគិតត្រឹមឆ្នាំ២០២៥កន្លងទៅ មានចំនួន ១០លើករួចមកហើយ ក្នុងគោលបំណងជំរុញ កៀរគរឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលគ្រប់ថ្នាក់ វិស័យឯកជន និងប្រជាពលរដ្ឋទូទាំងប្រទេស ដើម្បីប្រមូលផ្តុំកម្លាំងសរុប វិធានការសរុប បង្កើតឱ្យបាននូវចលនាជាតិរួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា។

ឆ្លងកាត់បទពិសោធក្នុងការអនុវត្តផែនការ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ចំនួន ១០លើកកន្លងទៅ (២០១៧-២០២៥) ពិនិត្យឃើញថា ជាជំហានៗផែនការយុទ្ធនាការនេះ បានក្លាយជាផែនទីបង្ហាញផ្លូវសម្រាប់កម្ពុជា សម្រេចនូវក្តីសង្ឃឹម **«កម្ពុជាគ្មានគ្រឿងញៀននាអនាគត»**។

ផែនការដែលមានលក្ខណៈជាយុទ្ធសាស្ត្រនេះ ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ចាត់តាំងអនុវត្តតាមតួនាទីនិងដែនសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ជាក់ស្តែងនៅក្នុងឆ្នាំ២០២៥កន្លងទៅនេះ សម្រេចបានកិច្ចការសំខាន់ៗមួយចំនួនដូចជាៈ (១) ជំរុញការផ្សព្វផ្សាយអប់រំយ៉ាងផុលផុស តាមគ្រប់មធ្យោបាយ គ្រប់រូបភាព និងដល់ទីកន្លែងសរុបចំនួន **២០៨ ៣១៨ លើក** ដែលមានអ្នកចូលរួមនិងទទួលសារអប់រំក្នុងម្នាក់អាចទទួលសារអប់រំលើសពីម្តង (តួលេខបូកយោងសរុបចំនួន **២៣ ៣០១ ៨៤២ អង្គ/នាក់**) ក្នុងនោះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានប្រើប្រាស់យុទ្ធវិធីនៃការអប់រំផ្សព្វផ្សាយតាមបែបទាន់សម័យ តាមប្រព័ន្ធឌីជីថល និងបានកៀរគរ វិស័យឯកជន សមាគម សិល្បៈ កីឡា និងអង្គការនានា ក្នុងការចូលរួមជាជនបង្គោលក្នុងការងារផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ព្រមទាំងរៀបចំ **«ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០២៥»** យ៉ាងអធិកអធម ប្រកបដោយខ្លឹមសារអត្ថន័យ និងបរិយាបន្ន (២) តាមរយៈការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់ ទីតាំងអាជីវកម្មសរុបចំនួន **១២ កន្លែង** ត្រូវបានបិទ (៣) បានបើកប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន **១០ ៧៤៣ ករណី** ដោយឃាត់ខ្លួនជនសង្ស័យសរុបចំនួន **២៧ ៨៨៤ នាក់** និងចាប់យកគ្រឿងញៀនគ្រប់ប្រភេទមានទម្ងន់ប្រមាណ **៥ ៨៩៧ គីឡូក្រាម** និងសារធាតុគីមីផ្សំប្រមាណ **៤២ ៨១៤ គីឡូក្រាម** (៤) បានបញ្ជូនអ្នកញៀនគ្រឿងញៀនទៅទទួលការព្យាបាល និងស្តារនីតិសម្បទាសរុបចំនួន **១៦ ២១៦ នាក់** បានធ្វើសមាហរណកម្មចូលក្នុងគ្រួសារនិងសហគមន៍វិញសរុបចំនួន **១០ ៦៤០ នាក់**។

លើសពីនេះទៀត គ្រប់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទបញ្ជាលេខ០១ បប ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើតេស្តមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធសរុបចំនួន **១៣១ ៤៧៣ នាក់** រកឃើញវិជ្ជមានចំនួន **១០៤ នាក់** បានរៀបចំបែបបទបញ្ចប់មុខតំណែង បណ្តេញចេញពីក្របខ័ណ្ឌចំនួន **១០៣ នាក់** និងកំពុងបន្តនីតិវិធីចំនួន **១ នាក់** ដែលនេះគឺជាការឆ្លើយតបទៅនឹងគោលការណ៍សម្អាតផ្ទះយើង និងសម្អាតចកចេញពីផ្ទៃបឹង របស់ប្រមុខរាជរដ្ឋាភិបាលសំដៅជំរុញអភិបាលកិច្ចភាពស្អាតស្អំ និងភាពជាគំរូនៃការអនុវត្តច្បាប់។

ទោះបីជាប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ទទួលបានលទ្ធផលជាវិជ្ជមានដូចបានរៀបរាប់ខាងលើនោះក្តី ប៉ុន្តែស្ថិតក្នុងបរិបទនៃនិន្នាការជាសកល កម្ពុជានៅតែប្រឈមយ៉ាងស្រួចស្រាល់ទៅនឹងបញ្ហាស្មុគស្មាញថ្មីៗមួយចំនួន ដែលជាការប្រែប្រួលប្រកបដោយកលល្បិចនៃក្រុមឧក្រិដ្ឋជនអន្តរជាតិ ទាំងរូបភាពនិងសកម្មភាព នៃការផលិតនិងកែច្នៃដោយបន្លយកសារធាតុគីមីបម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម យកមកសំយោគជាសារធាតុញៀនប្រភេទថ្មីៗ ដោយប្រើប្រាស់វិធីសាស្ត្រផលិតប្លែកៗតាមគោលដៅងាយបំភាន់សមត្ថកិច្ច ការផ្លាស់ប្តូរច្រក និងផ្លូវចរាចរ រួមទាំងរូបភាពនៃការនាំចូលឆ្លងកាត់ ការកែច្នៃផលិតជាដើម។ ក្តីបារម្ភដែលជាបញ្ហាប្រឈមពុំរើនិងកំពុងបង្កហានិភ័យដល់សង្គមជាតិនោះគឺ ការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍នៅតែបន្តកើតមាននៅឡើយ និងកំពុងតែទាមទារឱ្យចាត់វិធានការជាអាទិភាព ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពបានទាន់ពេលវេលា។

ដោយពិនិត្យឃើញថា មហន្តរាយដែលបណ្តាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀន នៅតែបន្តរីករាលដាល ទាំងនៅក្នុងតំបន់និងលើពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបន្ត ដាក់ចេញនូវ **ផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ឆ្នាំ២០២៦** ក្នុងគោលដៅ ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃគ្រឿងញៀន ព្រមទាំងកសាង សង្គមដែលមានសុខុមាលភាពនិងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងការពារកិត្តិយស កិត្យានុភាពជាតិ ដោយបានកំណត់នូវគោលការណ៍ និងវិធានការសំខាន់ៗដូចខាងក្រោម៖

## I. គោលការណ៍រួម

- បន្តពង្រឹង និងជំរុញ ចលនាជាតិ និងស្មារតីរួមទូទាំងប្រទេស ក្នុងការចាត់ទុកបញ្ហាគ្រឿងញៀន គឺជា បញ្ហារួមដែលត្រូវគ្រប់វិស័យ គ្រប់តួអង្គ និងគ្រប់ប្រជាពលរដ្ឋទាំងអស់ ត្រូវចូលរួមដោះស្រាយទាំងអស់គ្នា ស្របតាមទស្សនវិស័យ **«ចូលរួមទាំងអស់គ្នា ដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន»** ក្នុងគោលបំណងធ្វើ យ៉ាងណា កាត់ផ្តាច់ឫសគល់នៃគ្រឿងញៀនចេញពីសង្គមកម្ពុជា រារាំងទប់ស្កាត់ការវិវត្តវិលត្រឡប់នៃបញ្ហាគ្រឿងញៀន និងបញ្ចៀសប្រទេសកម្ពុជាឱ្យចាកចេញផុតពីគោលដៅនៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន និងមិនឱ្យឥទ្ធិពល ដ៏សាហាវនៃគ្រឿងញៀន ញាំញីបំផ្លិចបំផ្លាញសង្គមជាតិ ដើម្បីឆ្លើយតបទៅនឹងការប្តេជាចិត្តរបស់កម្ពុជា គឺការកសាង សង្គមមួយដែលបញ្ហាគ្រឿងញៀន លែងជាឧបសគ្គរាំងដល់ការអភិវឌ្ឍសង្គមជាតិ

- ពង្រឹងការអនុវត្តទិសដៅអាទិភាពការងារទាំង៥ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យបានសកម្មផុសផុល និងក្រោមស្មារតីទទួលខុសត្រូវខ្ពស់ ដោយរួមមាន (១) ការងារផ្សព្វផ្សាយអប់រំ (២) ការងារអនុវត្តច្បាប់ (៣) ការងារព្យាបាលនិងស្តារនីតិសម្បទា (៤) ការងារគ្រប់គ្រងសារធាតុញៀននិងសារធាតុគីមីផ្សំ និង (៥) ការងារពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- បន្តជំរុញអភិបាលកិច្ចល្អ ភាពស្អាតស្អំ និងភាពជាគំរូនៃការអនុវត្តច្បាប់របស់មន្ត្រីរាជការ និងកងកម្លាំង ប្រដាប់អាវុធ តាមរយៈការបន្តអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ចេញវិធានការម៉ឹងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាល ថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍ **«សម្អាតផ្ទះយើង»** និង គោលការណ៍ **«សម្អាតចកចេញពីផ្ទៃបឹង និង រក្សាផ្ទៃបឹងឱ្យថ្លាជាប្រចាំ»**

- ជំរុញលើកទឹកចិត្តពលរដ្ឋក្នុងសហគមន៍ទាំងអស់ តភ្ជាប់ជាស្ពានជាមួយសមត្ថកិច្ចក្នុងការសហការ យកគ្រឿងញៀនចេញពីសហគមន៍ តាមរយៈការប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន និងប្រព័ន្ធទូរស័ព្ទ Hotline ដើម្បីរាយការណ៍ពីករណីជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន ក្នុងមូលដ្ឋាន ព្រមទាំងពង្រឹងយន្តការឆ្លើយតបរបស់សមត្ថកិច្ចមូលដ្ឋានគ្រប់ថ្នាក់ឱ្យទាន់ពេលនិងមានប្រសិទ្ធភាព នៅពេលមានពលរដ្ឋរាយការណ៍

- បន្តយុទ្ធនាការបោសសម្អាត កាត់ផ្តាច់បណ្តាញ បង្ក្រាបឱ្យដល់ឫសគល់ និងចាត់វិធានការច្បាប់ដោយ គ្មានបន្ធូរបន្ថយចំពោះរាល់បទល្មើសគ្រឿងញៀន ស្របតាមទិសស្លោក **«៣កុំ ១រាយការណ៍៖ កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍»** សំដៅជំរុញប្រសិទ្ធភាពគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មាន សុវត្ថិភាព»** ព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការស្រាវជ្រាវបទល្មើសសម្អាតប្រាក់ ដែលពាក់ព័ន្ធនឹងគ្រឿងញៀន ដើម្បីកាត់ផ្តាច់ចរន្តហិរញ្ញវត្ថុផ្គត់ផ្គង់ដល់សកម្មភាពរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀន។

- ខិតខំកសាងស្តារធនធានមនុស្សឡើងវិញ ចំពោះអ្នកញៀនគ្រឿងញៀន តាមរយៈការបង្កើនប្រសិទ្ធភាពបន្សាបព្យាបាល និងស្តារនីតិសម្បទា តាមមជ្ឈមណ្ឌលរដ្ឋ ឯកជន និងតាមសហគមន៍ ដើម្បីធានាការធ្វើសមាហរណកម្មបានសុក្រឹតត្រឹមត្រូវ នឹងផ្តល់នូវធនធានមនុស្សចូលរស់នៅ និងបំពេញការងារក្នុងសង្គមឡើងវិញ

- ពង្រឹងនិងពង្រីកវិសាលភាពសហប្រតិបត្តិការឱ្យបានទូលំទូលាយ ជាមួយបណ្តាអង្គការជាតិ អន្តរជាតិ ស្ថាប័នអនុវត្តច្បាប់បរទេសជាដៃគូ ក្នុងការផ្លាស់ប្តូរព័ត៌មានបម្រើឱ្យវិធានការបង្ការ ទប់ស្កាត់បទល្មើសពីចម្ងាយ និងបណ្តាព័ត៌មាន បទពិសោធល្អៗបម្រើឱ្យការបង្ក្រាប ព្រមទាំងការជួយឧបត្ថម្ភគាំទ្រទាំងស្មារតី បច្ចេកទេស និងសម្ភារៈ

- យកចិត្តទុកដាក់កាត់បន្ថយហានិភ័យនៃសុខុមាលភាពរបស់យុវវ័យ និងនិន្នាការគ្រោះថ្នាក់នៃការធ្លាក់ចូលក្នុងអន្ទាក់នៃគ្រឿងញៀននាពេលអនាគត តាមរយៈការហាមឃាត់ដាច់ខាតនៃការប្រើប្រាស់បារីអេឡិចត្រូនិក និងស៊ីស្សា ដោយចាត់តាំងការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០២ បប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា សំដៅលុបបំបាត់ការរីករាលដាលការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

## II. វិធានការជាក់ស្តែង

### ១. វិធានការអប់រំ

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីស្នូលក្នុងការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការជំរុញការផ្សព្វផ្សាយអប់រំឱ្យមានលក្ខណៈទាក់ទាញ ទាន់សម័យ និងមានប្រសិទ្ធភាព ឱ្យបានទូលំទូលាយទៅដល់ពលរដ្ឋគ្រប់វ័យ គ្រប់ស្រទាប់ និងជនដែលងាយរងហានិភ័យ តាមរយៈគ្រប់មធ្យោបាយ ដូចជាកម្មវិធីទូរស័ព្ទដៃ NoDrug ប្រព័ន្ធឃោសនាផ្សព្វផ្សាយនានា ការបញ្ជ្រាបតាមព្រឹត្តិការណ៍កម្សាន្ត កីឡា សាសនា និងសារអប់រំតាមទីសាធារណៈ ផលិតផលផ្សេងៗ និងយានយន្តនានា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃគ្រឿងញៀនបានទូលំទូលាយ

- ក្រសួងព័ត៌មាន ត្រូវម្ចាស់ការ ចាត់ទុកការងារផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន ជាការងារចម្បង ដោយគិតលើការងារផលិត កម្មវិធីដូចជាវេទិកាតុមូល វីដេអូអប់រំខ្លី ចម្រៀងកម្សាន្ត ឬរឿងកំប្លែងបង្កប់អត្ថន័យអប់រំ ព្រមទាំងធ្វើការណែនាំដល់គ្រប់ស្ថានីយទូរទស្សន៍និងវិទ្យុទាំងអស់ ត្រូវមានម៉ោងពេលសម្រាប់ចាក់ផ្សាយមាតិកាទាំងនោះ និងមានសារអប់រំនៅតាមកញ្ចក់ទូរទស្សន៍នានា

- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពង្រឹងនិងពង្រីកសកម្មភាពអប់រំប្រឆាំងគ្រឿងញៀន បារីអេឡិចត្រូនិក និងស៊ីស្សាជាប្រចាំ សម្រាប់ឱ្យសិស្សានុសិស្សរៀនសូត្រនៅតាមគ្រប់កម្រិត គ្រប់គ្រឹះស្ថានសិក្សា ស្របតាមកម្មវិធីនៃកម្រិតសិក្សានីមួយៗ និងបញ្ជ្រាបទៅដល់កីឡាករ កីឡាការិនីរួមទាំងពង្រីកវិសាលភាពដល់សមាគមក្លឹបកីឡាគ្រប់ប្រភេទ ព្រមទាំងជំរុញកីឡាករ កីឡាការិនីល្បីៗ ចូលរួមជួយលើការងារផ្សព្វផ្សាយអប់រំ ដល់អ្នកគាំទ្រ និងមហាជន

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំកម្មវិធីអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់និយោជិត បុគ្គលិក កម្មករ កម្មការិនី នៅតាមរោងចក្រ សហគ្រាស សិប្បកម្ម និងការដ្ឋានសំណង់នានា

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវធ្វើការណែនាំដល់ក្រុមហ៊ុនទូរស័ព្ទផ្ញើសារអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់អ្នកប្រើប្រាស់ឱ្យបានញឹកញាប់ជាប់ជាប្រចាំ និងសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាឌីជីថលថ្មីៗ ដែលអាចជំរុញដល់ការងារផ្សព្វផ្សាយអប់រំឱ្យកាន់តែមានប្រសិទ្ធភាព

- ក្រសួងទេសចរណ៍ ត្រូវណែនាំឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងគោលដៅដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ខុនដូ ខេធីវី ផ្ទះសំណាក់ រួមទាំងកន្លែងកម្សាន្តសប្បាយនានា ត្រូវតាំងបិតនូវខ្លឹមសារអប់រំ និង/ឬ ការហាមចរាចរ ជួញដូរ និងប្រើប្រាស់គ្រឿងញៀន

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវសហការជាប់ប្រចាំជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការរៀបចំជាមាតិកាសិល្បៈទាក់ទាញនានា ដែលបង្កប់ន័យអប់រំពីបញ្ហាគ្រឿងញៀន ព្រមទាំងធ្វើការលើកទឹកចិត្តដល់សិល្បករនិងសិល្បការិនីទាំងអស់ ចូលរួមសម្តែង ផ្សព្វផ្សាយ និងធ្វើជាអ្នកផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន ដល់ទស្សនិកជន

- ក្រសួងធម្មការ និងសាសនា ត្រូវរៀបចំឱ្យមានកម្មវិធីបញ្ជ្រាបខ្លឹមសារអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមរយៈកម្មវិធីសាសនា ទាំងពុទ្ធសាសនា គ្រិស្តសាសនា ឥស្លាមសាសនា និងសាសនាដទៃទៀត

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំឱ្យមានព្រឹត្តិការណ៍ផ្សព្វផ្សាយអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានញឹកញាប់និងឱ្យអស់ពីលទ្ធភាព (មួយកន្លែងឱ្យបានយ៉ាងតិច២លើកក្នុងមួយខែ) តាមរយៈវេទិកាសាធារណៈ វេទិកាផ្សព្វផ្សាយគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** ឬវេទិកាផ្សេងៗទៀត។

## ២. វិធានការរដ្ឋបាល

ក្រសួងមហាផ្ទៃ ជាពិសេស គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចស្នូលក្នុងការអនុវត្តវិធានការរដ្ឋបាលយ៉ាងតឹងរ៉ឹង ម៉ត់ចត់ ក្នុងដែនសមត្ថកិច្ចខ្លួន ដោយក្នុងនោះត្រូវ៖

- ធ្វើបច្ចុប្បន្នភាពបញ្ជីគោលដៅដែលងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន និងត្រូវកោះអញ្ជើញម្ចាស់ទីតាំងឬអ្នកគ្រប់គ្រងអាជីវកម្មទាំងនោះ មកធ្វើការពន្យល់ណែនាំឱ្យយកចិត្តទុកដាក់ក្នុងការងារគ្រប់គ្រងឱ្យបានហ្មត់ចត់ ព្រមទាំងធ្វើកិច្ចសន្យាសហការបង្ការ ទប់ស្កាត់មិនឱ្យកើតមានបទល្មើសគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន

- ដឹកនាំកម្លាំងធ្វើរដ្ឋបាលក្នុងមូលដ្ឋាន ជាពិសេសកន្លែងមិនទាន់រៀបរយផ្សេងៗ រួមទាំងក្នុងក្លឹបកម្សាន្ត ខុនដូ បារ ខេធីវី ផ្ទះសំណាក់ ដោយត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងត្រូវអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់ម៉ឺងម៉ាត់ ដាច់ខាត ចំពោះទីតាំងអាជីវកម្មណាដែលបណ្តែតបណ្តោយឱ្យមានសកម្មភាពជួញដូរ និងប្រើប្រាស់គ្រឿងញៀន

- ត្រូវរៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ រោងចក្រ សហគ្រាស និងវិស័យឯកជននានា ដើម្បីប្រមូលផ្តុំកិច្ចសហការក្នុងការបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀន និងចូលរួមក្នុងចលនាគាំទ្រការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ដោយឡែក អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងពន្ធនាគារនិងមណ្ឌលអប់រំកែប្រែឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ ប្រកបដោយស្មារតីប្រុងប្រយ័ត្ននិងទទួលខុសត្រូវខ្ពស់ ដោយមិនត្រូវឱ្យមានការលួចនាំចូលគ្រឿងញៀនផ្តល់ឱ្យពិរុទ្ធជនឬទណ្ឌិត និង/ឬមានទំនាក់ទំនងពីក្នុងពន្ធនាគារចេញមកខាងក្រៅពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ ជាមួយគ្នានោះ ត្រូវពិចារណាលើវិធានការក្នុងការគ្រប់គ្រងជនល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀនឬសេពគ្រឿងញៀន ឱ្យនៅដាច់ដោយឡែកពីពិរុទ្ធជនឬទណ្ឌិតដទៃទៀត។

**៣. វិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម**

- ក្រសួងសុខាភិបាល ត្រូវដើរតួនាទីស្នូលលើការងារពង្រឹងប្រសិទ្ធភាព បន្សាបព្យាបាល អ្នកញៀនគ្រឿងញៀន ដោយត្រូវខិតខំបន្តស្រាវជ្រាវវិធីសាស្ត្របន្សាបព្យាបាលថ្មីៗ និងលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈដល់បុគ្គលិកសុខាភិបាលក្នុងការងារបន្សាបព្យាបាល

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវប្រកាសដាក់ឱ្យដំណើរការនិងអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាទាំងរដ្ឋនិងឯកជន សំដៅធ្វើយ៉ាងណាឱ្យមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាទាំងអស់ ក្លាយជាកន្លែងកសាងធនធានមនុស្សឡើងវិញដ៏មានប្រសិទ្ធភាព សម្រាប់ការធ្វើសមាហរណកម្មចូលក្នុងសង្គម

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹងនិងពង្រីកសមត្ថភាពមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះ ដែលប្រមូលបានឬរកឃើញតាមរយៈការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់ក្នុងយុទ្ធនាការនេះ និង/ឬតាមការស្នើសុំដោយស្ម័គ្រចិត្តពីសំណាក់ក្រុមគ្រួសារនិងជនរងគ្រោះ

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយជនដែលញៀនគ្រឿងញៀនក្នុងការស្វែងរកការងារធ្វើ ក្រោយចាកចេញពីមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវចាប់ផ្តើមដំណើរការប្រព័ន្ធទិន្នន័យឌីជីថលសម្រាប់គ្រប់គ្រងអ្នកញៀនគ្រឿងញៀន តាមមជ្ឈមណ្ឌលនិងក្នុងសហគមន៍ ដោយក្នុងនោះគ្រប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាទាំងរដ្ឋនិងឯកជន ត្រូវសហការក្នុងការបញ្ចូលទិន្នន័យអ្នកញៀនក្នុងមជ្ឈមណ្ឌលរបស់ខ្លួន ដើម្បីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានទិន្នន័យច្បាស់លាស់ និងងាយស្រួលតាមដានដល់ប្រសិទ្ធភាពនៃការព្យាបាល និងគ្រប់គ្រងអ្នកញៀនតាមមជ្ឈមណ្ឌលនីមួយៗ

- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន ដោយត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់អំពីមុខសញ្ញាប្រើប្រាស់ និងងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន។ ទន្ទឹមគ្នានោះ ត្រូវជំរុញនិងលើកទឹកចិត្តអ្នកដែលមិនទាន់ទទួលបានការព្យាបាល ឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រងចំពោះបុគ្គលដែលបានធ្វើសមាហរណកម្មចូលក្នុងសហគមន៍ បន្ទាប់ពីចាកចេញពីមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅមូលដ្ឋានរបស់ខ្លួន ជាមួយគ្នានោះ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ត្រូវសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីបង្កលក្ខណសម្បត្តិលើកទឹកចិត្តដល់វិស័យឯកជនចូលរួម និង/ឬកសាងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយត្រូវអនុលោមតាមនិយាមនីតិវិធីប្រតិបត្តិ សម្រាប់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៤. វិធានការអនុវត្តច្បាប់**

ការងារអនុវត្តច្បាប់ប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ គឺជាសមត្ថកិច្ចស្នូលរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងគណៈបញ្ជាការឯកភាពរាជធានីខេត្ត ដោយផ្តោតទៅលើការបង្ក្រាប ការជួញដូរ ការចែកចាយ ការប្រើប្រាស់ក្នុងសហគមន៍ ការនាំចូលតាមច្រកគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍ ការលបលួចលាក់កែច្នៃផលិត និងការរក្សាទុកត្រៀមបញ្ជូនទៅប្រទេសទីបី។ សមត្ថកិច្ចដែលពាក់ព័ន្ធដល់ការងារបង្ក្រាប ត្រូវយកចិត្តទុកដាក់លើការងារមួយចំនួនដូចជា៖

- រៀបចំផែនការសកម្មភាពដើម្បីត្រួតពិនិត្យជាប្រចាំ និងបើកប្រតិបត្តិការបោសសម្អាតបណ្តាញឧក្រិដ្ឋជនជួញដូរគ្រឿងញៀន និងត្រូវអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់បំផុត ដោយត្រូវបន្តស្រាវជ្រាវរកប្រភពនៃគ្រឿងញៀន និងក្រុមមេក្លោង បណ្តាញខ្សែរយៈ ដើម្បីបំផ្លាញឱ្យដល់ឫសគល់ និងបញ្ចៀសឱ្យបានដាច់ខាតកុំឱ្យមានវត្តមានបណ្តាញក្រុមអង្គការចាត់តាំងគ្រឿងញៀនអន្តរជាតិនៅកម្ពុជា ព្រមទាំងពន្លាតនីតិវិធីប្រឆាំងការសម្អាតប្រាក់

- ឆ្លើយតបបានរហ័សទាន់ពេលនិងមានប្រសិទ្ធភាព នៅពេលមានពលរដ្ឋរាយការណ៍តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ឬប្រព័ន្ធ Hotline ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀនក្នុងសហគមន៍របស់ពលរដ្ឋ ឈានទៅសម្រេចបានភូមិ ឃុំសង្កាត់ ស ស្អាតគ្មានគ្រឿងញៀន និងបង្កើនទំនុកចិត្តរបស់ពលរដ្ឋមកលើសមត្ថកិច្ច

- តាមដាន គ្រប់គ្រង និងបង្ក្រាបឱ្យបានម៉ឺងម៉ាត់នូវសកម្មភាពកែច្នៃផលិតគ្រឿងញៀនសំយោគ ការដាំដុះ ការចម្រាញ់ ការនាំចូលវត្ថុធាតុដើមជាសារធាតុគីមីផ្សំ ដែលអាចកែច្នៃផលិតគ្រឿងញៀនសំយោគ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងត្រូវពង្រឹងការអនុវត្តនិយាមនីតិវិធីប្រតិបត្តិស្តីពីការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំឱ្យមានប្រសិទ្ធភាព

- សហការទប់ស្កាត់លំហូរចូលគ្រឿងញៀនពីបរទេស ជាពិសេសបច្ចុប្បន្នតាមលំហូរព្រំដែនគោក ដោយក្នុងនោះ រដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង ត្រូវខិតខំសហការគ្នា ដើម្បីផ្លាស់ប្តូរព័ត៌មាន និងស៊ើបអង្កេតរកមុខសញ្ញា ឈានទៅបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមព្រំដែន ព្រមទាំងពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដើម្បីជំរុញលើកទឹកចិត្តឱ្យមានកិច្ចសហការរួមគ្នាក្នុងការផ្តល់ព័ត៌មាននិងផ្លាស់ប្តូរសភាពការណ៍ជាប់ជាប្រចាំ។

- សម្របសម្រួល ដើម្បីជំរុញកិច្ចពិគ្រោះពិភាក្សារវាងស្ថាប័នអយ្យការ តុលាការ ជាមួយអង្គភាពនគរបាល និងកងរាជអាវុធហត្ថ ដើម្បីធ្វើឱ្យកិច្ចសហការកាន់តែមានដំណើរការរលូន លុបបំបាត់និទណ្ឌភាព និងពង្រឹងនីតិវិធីក្នុងការកសាងសំណុំរឿងឱ្យបានរឹងមាំ ដើម្បីធានាដល់ការផ្តន្ទាទោសមេក្លោងនិងបណ្តាញជួញដូរគ្រឿងញៀន។

**៥. គោលការណ៍សម្អាតផ្ទះយើង និងសម្អាតចកចេញពីផ្ទៃបឹង**

គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមអនុវត្តគោលការណ៍ **«សម្អាតផ្ទះយើង»** និង **«សម្អាតចកចេញពីផ្ទៃបឹង»** ដោយត្រូវបន្តយកចិត្តទុកដាក់ចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ នូវបទបញ្ជារបស់រាជរដ្ឋាភិបាលចំនួន ២ ដូចខាងក្រោម៖



៩

- បទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ចេញវិធានការម៉ឹងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបន្តធ្វើតេស្តរកសារធាតុញៀនទៅលើមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងចាត់វិធានការបញ្ឈប់មុខតំណែង បណ្តេញចេញពីក្របខ័ណ្ឌចំពោះករណីវិជ្ជមាន និងត្រូវបន្តអនុវត្តទៀងទាត់ជាប់ជាប្រចាំ ដោយមានការតាមដានការអនុវត្តពីសំណាក់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០២ បប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ក្នុងនោះត្រូវចាត់វិធានការស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ចំពោះបុគ្គលណាដែលបានចែកចាយ លក់ ស្តុកទុក ផ្សព្វផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយលក់ផលិតផល និង/ឬនាំចូលឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា និងត្រូវចាត់វិធានការដាក់ទណ្ឌកម្មរដ្ឋបាល ចំពោះមន្ត្រីទាំងឡាយណាដែលប្រើប្រាស់ និង/ឬមានការពាក់ព័ន្ធនឹងឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ក្នុងគោលបំណងបង្ការទប់ស្កាត់ កុំឱ្យមានការរីវឌ្ឍការប្រើប្រាស់ឧបករណ៍ទាំងនេះ ទៅជាការប្រើប្រាស់គ្រឿងញៀននាពេលអនាគត។

### ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិគ្រប់កម្រិត ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពយន្តការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធ និងជំរុញកិច្ចសហការជំនួយលើសម្ភារៈបច្ចេកទេស និងបណ្តុះបណ្តាល ព្រមទាំងចូលរួមផ្សព្វផ្សាយពីសមិទ្ធផលកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនទៅកាន់វេទិកាអន្តរជាតិ ដើម្បីលើកកិត្តិនាម និងបង្ហាញពីឆន្ទៈមោះមុតរបស់កម្ពុជាលើវិស័យនេះ ដោយក្នុងនោះ៖

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គភាពពាក់ព័ន្ធនានា ត្រូវបន្តបើកទូលាយកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយប្រទេសជិតខាង ក៏ដូចជាអង្គការអន្តរជាតិសំខាន់ៗ ដើម្បីក្តាប់ជាប់និន្នាការប្រែប្រួលតាមដំណាក់កាលនីមួយៗ ក្តាប់បានអំពីខ្សែរយៈទំនាក់ទំនង និងបែបផែនសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀន សំដៅមានភាពម្ចាស់ការដាក់ចេញវិធានការទប់ស្កាត់ពីចម្ងាយ និង/ឬធ្វើការបង្ក្រាបបានទាន់ពេល ក្នុងនោះត្រូវយកចិត្តទុកដាក់ទាំងកិច្ចសហប្រតិបត្តិការថ្នាក់ជំនាញនិងមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដែលឈរជើងតាមព្រំដែន ព្រមទាំងលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញ និងទទួលបានការគាំទ្រទាំងស្មារតី ឧបករណ៍ និងសម្ភារៈបច្ចេកទេស ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បន្តចូលរួមសកម្មភាពដែលផ្សារភ្ជាប់ជាមួយនឹងសហគមន៍អន្តរជាតិ ដូចជាការរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ឱ្យបានទៀងទាត់និងអធិកអធមជារៀងរាល់ឆ្នាំ ការចូលរួមក្នុងវេទិកាសន្និសីទ សិក្ខាសាលា ថ្នាក់អន្តរជាតិ និងតំបន់នានា ដើម្បីបង្ហាញទៅអន្តរជាតិឱ្យបានឃើញអំពីសុច្ឆន្ទៈ និងការប្តេជ្ញាចិត្តមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## III. ការចាត់តាំងអនុវត្ត

ដើម្បីអនុវត្តផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ចាំបាច់ត្រូវមានការចាត់តាំងអនុវត្តដូចខាងក្រោម៖

១. គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នេះ ដឹកនាំដោយ ឯកឧត្តម សន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ជាប្រធាន** និង ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាអនុប្រធាន**។

២. គណៈបញ្ជាការដឹកនាំយុទ្ធនាការ អាចពិនិត្យនិងធ្វើបច្ចុប្បន្នភាពឡើងវិញ នូវសមាសភាពមួយចំនួនរបស់គណៈកម្មការចម្រុះនិងលេខាធិការដ្ឋាន ដូចបានកំណត់ក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៩ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

៣. គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវកសាងផែនការសកម្មភាពជាក់ស្តែង តាមវិស័យនិងតាមភូមិសាស្ត្រនីមួយៗ និងតាមដែនសមត្ថកិច្ចរៀងៗខ្លួន ដើម្បីចាត់តាំងអនុវត្តបានសម្រេចជោគជ័យ ស្របតាមគោលបំណងនិងសំណូមពរនៃយុទ្ធនាការ។

៤. ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់បណ្តាអង្គភាព និងបុគ្គលដែលមានស្នាដៃល្អក្នុងការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ព្រមទាំងមានវិធានការអនុវត្តវិន័យ ឬវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវនិងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១១រោច ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣៦....សហវ.

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស សម្រាប់បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ជូនមន្ត្រីរាជការប្រចាំនៅអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ .-**

ប្រាក់បៀវត្សមន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ របស់ក្រសួងមុខងារសាធារណៈ ត្រូវបើកផ្ដល់តាមរយៈភ្នាក់ងារបើកផ្ដល់។

**ប្រការ២ .-**

ត្រូវបានតែងតាំងភ្នាក់ងារបើកផ្ដល់ និងភ្នាក់ងារបើកផ្ដល់ជំនួស របស់អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ ដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃក្រសួងមុខងារសាធារណៈ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១.លោក | **វ៉ែត ច័ន្ទធីរៈ** | មុខងារ មន្ត្រី ជាភ្នាក់ងារបើកផ្ដល់ ប្រចាំនៅអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ |
| ២.លោកស្រី | **តូ ស៊ីនឡាង** | មុខងារ មន្ត្រី ជាភ្នាក់ងារបើកផ្ដល់ជំនួស ប្រចាំនៅអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ។ |

២/៣

**ប្រការ៣ .-**

លោក **រ៉េត ច័ន្ទវីរៈ** ជាភ្នាក់ងារបើកផ្តល់ និងលោកស្រី **គូ ស៊ីនឡាង** ជាភ្នាក់ងារបើកផ្តល់ជំនួស ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីទទួលមូលនិធិ សម្រាប់យកទៅបើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ជូនមន្ត្រីរាជការ។

**ប្រការ៤ .-**

បែបបទនៃការអនុវត្តបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ។

**ប្រការ៥ .-**

ភ្នាក់ងារបើកផ្តល់ ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលទទួលបាន ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible]ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

ហ៊ុន-ម៉ានិ

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ *
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០៣៤...សហវ.ប្រក. [illegible]

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងរដ្ឋលេខាធិការបុរេប្រទាន នៅអគ្គាធិការដ្ឋាន ជាអាណាប័កផ្ទេរសិទ្ធិពេញលេញ នៃក្រសួងមុខងារសាធារណៈ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ

១/៣

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម្មលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១៥៩៩ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងមន្ត្រីរាជការរបស់អគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈដូចខាងក្រោម៖

| | |
|---|---|
| ១.លោក **ម៉ុត សារៈ** | មុខងារ ប្រធានលេខាធិការដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទាន ប្រចាំនៅអគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ |
| ២.លោក **សុខ ដារ៉ា** | មុខងារ អនុប្រធានលេខាធិការដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទានរង ប្រចាំនៅអគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ |
| ៣.លោកស្រី **ឆាម ច័ន្ទស្រីនី** | មុខងារ អនុប្រធានលេខាធិការដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទានរង ប្រចាំនៅអគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ។ |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង អគ្គាធិការដ្ឋាន នៃក្រសួងមុខងារសាធារណៈ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងមុខងារសាធារណៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១៣រោច ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

ហ៊ុន ម៉ានិ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤១៣...ឧវបន.ឧក...ប្រក

ថ្ងៃ សុក្រ ៣ កើត ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២៥

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៧១៤/១៨ ម.ត.ស.ព ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតរោងចក្រដំឡើងទោចក្រយាន ទោចក្រយានអគ្គិសនី និងផលិតគ្រឿងបង្គុំទោចក្រយាន របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន អេវើហ្គ្រេន បាយស៊ីខល (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អេវើហ្គ្រេន បាយស៊ីខល (ខេមបូឌា) ឯ.ក (**EVERGRAND BICYCLE (CAMBODIA) CO., LTD.**) តំណាងដោយលោក **MA, CHUNMING** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EA9454587** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ បង្កើតរោងចក្រដំឡើងទោចក្រយាន ទោចក្រយានអគ្គិសនី និងផលិតគ្រឿងបង្គុំទោចក្រយាន ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន (ស្វាយរៀង) ផ្លូវជាតិលេខ១ ភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ទោចក្រយាន ទោចក្រយានអគ្គិសនី និងគ្រឿងបង្គុំទោចក្រយាន | ៣០៩២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រដំឡើងទោចក្រយាន ទោចក្រយានអគ្គិសនី និងផលិតគ្រឿងបង្គុំទោចក្រយាន អេវើហ្វ្រេន បាយស៊ីខល (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៦៥១ ឧវបន.កឧ.ប្រក.១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**បម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- សាលាខេត្តស្វាយរៀង
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្វាយរៀង
- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មេនហាត ពេន (ស្វាយរៀង)
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ឧ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ទឹម ស៊ីនី

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី